ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

## ការណែនាំអនុវត្ត

# ការធ្វើតេស្តប្រចាំខែ
# សម្រាប់សាលារៀនបឋមសិក្សា

ខែមេសា ឆ្នាំ២០១៨

# មាតិកា


សេចក្តីផ្តើម

គោលបំណង

យន្តការវាយតម្លៃការសិក្សារបស់សិស្សនៅសាលារៀន

ក. ការរៀបចំសំណួរតេស្តប្រចាំខែ

ខ. ការរៀបចំកម្មវិធី និងកាលវិភាគធ្វើតេស្តសិស្សប្រចាំខែនៅសាលារៀន

គ. ការរៀបចំដំណើរការធ្វើតេស្តប្រចាំខែនៅសាលារៀន

ឃ. ការផ្តល់ព័ត៌មានត្រឡប់ក្រោយពីការធ្វើតេស្តប្រចាំខែនៅសាលារៀន

ង. សកម្មភាពហ្វឹកហាត់ជួយសិស្សរៀនយឺត និងរៀនលឿន

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ឯកសារការណែនាំអនុវត្ត **ការធ្វើតេស្តប្រចាំខែ សម្រាប់សាលារៀនបឋមសិក្សា** គឺជាផ្នែកមួយដ៏សំខាន់ ក្នុងចំណោមផ្នែកផ្សេងទៀត ក្នុងការរួមចំណែកពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងបច្ចេកទេសនៅសាលារៀន ដែលអាចធានាបានលទ្ធផលសិក្សារបស់សិស្សឆ្លើយតបទៅនឹងស្តង់ដាកម្មវិធីសិក្សា ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ការគ្រប់គ្រងការធ្វើតេស្ត នៅតាមសាលារៀនមានវិន័យ សណ្តាប់ធ្នាប់ល្អ និងមានប្រសិទ្ធភាពខ្ពស់ គឺអាចទាក់ទាញឱ្យអាណាព្យាបាលសិស្ស និងសហគមន៍ចូលរួមអភិវឌ្ឍន៍សាលារៀន ព្រមទាំងគាំទ្រដល់សកម្មភាពបង្រៀនសិស្សរបស់លោកគ្រូអ្នកគ្រូ ប្រកបដោយមោទនភាពផងដែរ។ កិច្ចការសំខាន់ៗក្នុងការធ្វើតេស្តសិស្ស ដែលសាលារៀនចាំបាច់ត្រូវអនុវត្តឱ្យបានរួមមាន៖

- ការរៀបចំសំណួរតេស្តប្រចាំខែ ដែលមានទំនាក់ទំនងទៅនឹងសំណួរតេស្តឆមាស ដើមឆ្នាំ និងចុងឆ្នាំ ដោយផ្អែកលើកម្មវិធីសិក្សាលម្អិត ដែលរៀបចំទៅតាមលំដាប់លំដោយទម្រង់ និងគោលការណ៍របស់ប្លូមទាំង ៦កម្រិត។

- រៀបចំកម្មវិធី និងកាលវិភាគធ្វើតេស្តសិស្ស ដោយផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីអាចឱ្យសិស្សានុសិស្សយកចិត្តទុកដាក់ក្នុងការសិក្សា គ្រូបង្រៀនខិតខំរិះរកវិធីសាស្ត្របង្រៀនថ្មីៗបន្ថែម ជាពិសេសវិធីជួយសិស្សរៀនយឺត ដែលអាណាព្យាបាលនិងសហគមន៍មានចំណាប់អារម្មណ៍ទៅលើអន្តរាគមន៍របស់សាលារៀនក្នុងការអនុវត្តតេស្ត។

- រៀបចំដំណើរការធ្វើតេស្ត ដោយចាត់តាំងគ្រូបង្រៀន និងបុគ្គលិកសិក្សាទាំងអស់ធ្វើជាអនុរក្ស ជាអ្នកត្រួតពិនិត្យក្នុងដំណើរការធ្វើតេស្ត ជាអ្នករក្សាវិន័យនិងសណ្តាប់ធ្នាប់ក្នុងដំណើរការធ្វើតេស្ត ជាអ្នកកែកិច្ចការតេស្ត និងជាអ្នកសរុបលទ្ធផលតេស្តសិស្សតាមថ្នាក់ និងតាមមុខវិជ្ជានីមួយៗ។

- ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សរៀនយឺត និងសិស្សរៀនលឿន ដោយទំនាក់ទំនងផ្ទាល់ជាមួយអាណាព្យាបាលសិស្សរៀនយឺត និងសិស្សរៀនលឿន ដើម្បីរាយការណ៍និងសហការជាមួយសហគមន៍ ដើម្បីរៀបចំកម្មវិធីជួយសិស្សរៀនយឺត និងរៀនលឿននៅក្នុងសាលារៀន និងនៅក្នុងសហគមន៍។

ដូច្នេះឯកសារការណែនាំអនុវត្ត **ការធ្វើតេស្តប្រចាំខែ សម្រាប់សាលារៀនបឋមសិក្សា** នឹងអាចជួយឱ្យសាលារៀនមានលទ្ធភាពបង្កើនលទ្ធផលសិក្សារបស់សិស្ស ឱ្យកាន់តែខ្ពស់មួយកម្រិតទៀត តាមរយៈការខិតខំប្រឹងប្រែងផ្លាស់ប្តូរការងារធ្វើតេស្តកម្រិតសាលារៀនរបស់គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនក្នុងការងារវាយតម្លៃការសិក្សារបស់សិស្សក្នុងដំណើរការបង្រៀនប្រចាំថ្ងៃ។

# គោលបំណង

ជួយសាលារៀនឱ្យមាន ប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សា នៅកម្រិតសាលារៀន ផ្តោតលើការវាយតម្លៃការសិក្សារបស់សិស្សដែលអនុវត្តដោយគ្រូបង្រៀនតាមថ្នាក់ ដើម្បីរួមចំណែកក្នុងការបង្កើនលទ្ធផលធ្វើតេស្តស្តង់ដាប្រចាំខែរបស់សាលារៀន ឆ្លើយតបទៅនឹងគោលដៅអប់រំជាតិ គោលដៅអប់រំចំណេះទូទៅ លទ្ធផលសិក្សា និងស្តង់ដាកម្មវិធីសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា។

ជួយគ្រូបង្រៀនតាមកម្រិតថ្នាក់៖

- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រចាំសប្តាហ៍ ដើម្បីត្រៀមធ្វើតេស្តប្រចាំខែ។
- បង្កើតឧបករណ៍តេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែ ជាមួយគ្រូបង្រៀនគ្រប់កម្រិតថ្នាក់។
- ចូលរួមក្នុងសកម្មភាពធ្វើតេស្តលទ្ធផលសិក្សារបស់សិស្ស ប្រចាំខែកម្រិតសាលារៀន។
- កត់ត្រាលទ្ធផលតេស្តប្រចាំខែ ដើម្បីអាចកំណត់ការប្រែប្រួលលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ។
- ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស និងអាណាព្យាបាលសិស្សរៀនយឺត និងរៀនលឿន។
- រៀបចំសកម្មភាពអន្តរាគមន៍ផ្សេងៗ ដើម្បីជួយសិស្សរៀនយឺត និងរៀនលឿននៅកម្រិតថ្នាក់រៀន និងតាមក្លិបសិក្សា។

ជួយគណៈគ្រប់គ្រងសាលារៀន៖

- ដឹកនាំការធ្វើតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែ កម្រិតសាលារៀន។
- សរុបលទ្ធផលតេស្តប្រចាំខែ របស់សិស្សតាមកម្រិតថ្នាក់នីមួយៗ។
- ផ្សព្វផ្សាយលទ្ធផលសិក្សា ប្រចាំខែរបស់សិស្សតាមកម្រិតថ្នាក់នីមួយៗដល់សហគមន៍ និងអ្នកពាក់ព័ន្ធ។
- អន្តរាគមន៍ជួយសិស្សរៀនយឺតកម្រិតសាលារៀន និងសហគមន៍។

# យន្តការវាយតម្លៃការសិក្សារបស់សិស្សនៅសាលារៀន

គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយសិស្សឱ្យចេះរៀនដោយខ្លួនឯង និងមានទម្លាប់រៀនពេញមួយជីវិត ដែលជាមូលដ្ឋានគ្រឹះដើម្បីបង្កើនលទ្ធផលសិក្សាជាប្រចាំ តាមរយៈការធ្វើតេស្តកម្រិតសាលារៀន និងកម្រិតផ្សេងទៀតក្រៅពីការធ្វើតេស្តនៅសាលារៀន។ ដូច្នេះមធ្យោបាយមួយដ៏ប្រសើរបំផុត ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សគឺ៖ (១)ពង្រឹងការវាយតម្លៃការសិក្សារបស់សិស្សកម្រិតថ្នាក់រៀន (២)ពង្រឹងការអនុវត្តតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែនៅកម្រិតសាលារៀន។

គណៈគ្រប់គ្រង និងគ្រូបង្រៀនក្នុងសាលារៀន រួមគ្នារៀបចំឱ្យមានយន្តការវាយតម្លៃកម្រិតថ្នាក់រៀន និងសាលារៀន ដោយកំណត់តួនាទី និងភារកិច្ចរបស់ខ្លួនដូចតទៅ៖ (១)គ្រូបង្រៀនម្នាក់ៗទទួលខុសត្រូវវាយតម្លៃសកម្មភាពសិក្សារបស់សិស្សក្នុងដំណើរការបង្រៀន ពេលរៀនចប់មេរៀនមួយ និងការធ្វើតេស្តសិស្សប្រចាំសប្តាហ៍ ព្រមទាំងសកម្មភាពតេស្តផ្សេងទៀតដែលសាលារៀនបានរៀបចំ (២)គណៈគ្រងគ្រងសាលារៀនទទួលខុសត្រូវលើការធ្វើតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែ និងតេស្តផ្សេងទៀតក្នុងសាលារៀន ក្រៅពីនេះគណៈគ្រប់គ្រងសាលារៀន ក៏អាចវាយតម្លៃប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូម្នាក់ៗដោយផ្អែកលើលទ្ធផលសិក្សារបស់សិស្សផងដែរ។

ដើម្បីធានាបានលទ្ធផលសិក្សារបស់សិស្សមានប្រសិទ្ធភាពខ្ពស់ គណៈគ្រប់គ្រងសាលារៀនត្រូវដឹកនាំធ្វើកម្មវិធី និងផែនការតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំឆ្នាំ ដោយមានការចូលរួមពីគ្រូបង្រៀន ក្រុមប្រឹក្សាកុមារ អាណាព្យាបាលសិស្ស និងតំណាងសហគមន៍។ កម្មវិធី និងផែនការតេស្តផ្តោតទៅលើ (១)ការធ្វើតេស្តប្រចាំខែដែលដឹកនាំ គ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់ពីគណៈគ្រប់គ្រងសាលារៀន (២)ការធ្វើតេស្តឆមាស ដែលដឹកនាំ និងគ្រប់គ្រងផ្ទាល់ពីគណៈគ្រប់គ្រងសាលារៀន ដោយមានការត្រួតពិនិត្យបច្ចេកទេសពីការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត (៣)ការធ្វើតេស្តដើមឆ្នាំ និងចុងឆ្នាំ ដែលដឹកនាំ និងគ្រប់គ្រងផ្ទាល់ពីគណៈគ្រប់គ្រងសាលារៀន ដោយមានការត្រួតពិនិត្យបច្ចេកទេសពីការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត។

# ក ការរៀបចំសំណួរតេស្តប្រចាំខែ

គណៈគ្រប់គ្រងសាលារៀនជាអ្នកដឹកនាំផ្ទាល់ដោយកំណត់ពេលវេលា ទីកន្លែងសមស្រប និងសហការជាមួយគ្រូបង្រៀនទាំងអស់ក្នុងសាលារៀន ដើម្បីតាក់តែងសំណួរតេស្តប្រចាំខែទៅតាមកម្រិតថ្នាក់នីមួយៗឱ្យមានប្រសិទ្ធភាពខ្ពស់។

សំណួរតេស្តប្រចាំខែ ដែលគ្រូបង្រៀនសរសេរបាន ត្រូវប្រគល់ជូនគណៈគ្រប់គ្រងសាលារៀន មុនពេលធ្វើតេស្តយ៉ាងតិចមុនមួយខែ។ ប្រសិនបើគ្រូបង្រៀន និងក្រុមបច្ចេកទេសអាចធ្វើសំណួរតេស្តប្រចាំខែសម្រាប់មួយឆ្នាំសិក្សាបាន ត្រូវប្រគល់ជូនគណៈគ្រប់គ្រងសាលារៀន សម្រាប់រៀបចំការធ្វើតេស្តប្រចាំខែពេញមួយឆ្នាំសិក្សាតែម្តង។ ការអនុវត្តបែបនេះ អាចជួយឱ្យសាលារៀនកសាងបាននូវ ធនាគារសំណួរតេស្តប្រចាំខែសម្រាប់មួយឆ្នាំសិក្សា ដែលជាបច្ច័យល្អសម្រាប់ការបន្តធ្វើបច្ចុប្បន្នភាពជាបណ្តើរៗតាមខែនីមួយៗក្នុងករណីចាំបាច់។

ជាក់ស្ដែងពេលដែលគ្រូបង្រៀនទាំងអស់ បានសរសេរសំណួរតេស្ដប្រចាំខែ គឺជាកិច្ចការមួយបានជួយបង្កើន ការយល់ដឹងអំពីការអនុវត្តកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងឯកសារណែនាំទាក់ទងនឹងការងារគ្រប់គ្រង បច្ចេកទេសរៀន និងបង្រៀនមួយចំនួនទៀត ដែលក្រសួងអប់រំ យុវជន និងកីឡាបានផ្សព្វផ្សាយកន្លងមក។ ដូច្នេះ សំណួរតេស្ដប្រចាំខែដែលគ្រូបង្រៀនបានតាក់តែងរួចជាស្រេចក៏បានបង្ហាញពីវិធីសាស្ត្របង្រៀនមួយចំនួនធំផងដែរ ដែលគ្រូអាចប្រើសម្រាប់ដឹកនាំសកម្មភាពបង្រៀនសិស្ស។

## ១. ការបង្កើតគម្រោងលម្អិតតេស្តប្រចាំខែ កម្រិតសាលារៀន

គណៈគ្រប់គ្រងសាលារៀន ដឹកនាំគ្រូបង្រៀនតាមថ្នាក់នីមួយៗ ធ្វើការរួមគ្នាតាក់តែងបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ ដោយសិក្សាខ្លឹមសារឯកសារសំខាន់ៗមួយចំនួនដូចជា៖ (១)កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅមានប្រាប់ពីចំនួនម៉ោងសិក្សាឬម៉ោងបង្រៀន (២)កម្មវិធីសិក្សាលម្អិតសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅមានប្រាប់ពីលទ្ធផលសិក្សានិងស្តង់ដាលទ្ធផលសិក្សាតាមកម្រិតថ្នាក់ និងគ្រប់មេរៀនទាំងអស់ និង(៣)សៀវភៅសិក្សាគោលមានប្រាប់ពីខ្លឹមសារ សកម្មភាព និងលំហាត់ដែលសិស្សត្រូវរៀន។ (សូមមើលឧទាហរណ៍ **គំរូបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា** ក្នុងឧបសម្ព័ន្ធទី១)

ដូច្នេះការរៀបចំគម្រោងលម្អិតតេស្តវង្វាយតម្លៃប្រចាំខែ គឺត្រូវស្របទៅនឹងបំណែងចែកកម្មវិធីសិក្សា ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១។ គម្រោងលម្អិតតេស្ត គឺជាសេចក្តីសង្ខេប ឬជាតារាងលម្អិតបង្ហាញពីលទ្ធផលសិក្សាដែលត្រូវស្រង់ចេញពីកម្មវិធីសិក្សាលម្អិត និងខ្លឹមសារមេរៀនសំខាន់ៗពីក្នុងសៀវភៅសិក្សាគោល។ (សូមមើលឧទាហរណ៍ **គម្រោងលម្អិតតេស្ត** សម្រាប់វិញ្ញាសាប្រឡងប្រចាំខែ ក្នុងឧបសម្ព័ន្ធទី២)

ជាធម្មតានៅក្នុងគម្រោងលម្អិតតេស្តវង្វាយតម្លៃដែលល្អ ត្រូវបញ្ជាក់ពីចំណុចមួយចំនួន ដូចខាងក្រោម៖

- ចំនួនលទ្ធផលសិក្សាអាទិភាព និងឬស្តង់ដារសិក្សាអាទិភាព ដែលត្រូវយកមកធ្វើតេស្ត
- ចំនួនសំណួរតេស្តតំណាងឱ្យលទ្ធផលសិក្សានីមួយៗ (ឧទាហរណ៍៖ សម្រាប់ភាសាខ្មែរសំណួរតេស្តចំនួន ៦ ដែលត្រូវប្រើដើម្បីវាស់លទ្ធផលសិក្សា«គុណកិរិយា»(
- សមាមាត្រនៃកម្រិតសំណួរតេស្ត ឧទាហរណ៍៖ កម្រិតងាយ) ២០% កម្រិតមធ្យម ៦០% និង កម្រិតលំបាក ២០(%
- សមាមាត្រនៃកម្រិតពុទ្ធិរបស់សំណួរតេស្ត ឧទាហរណ៍៖ កម្រិតពុទ្ធិតាមលោក)Bloom រួមមាន៖ ចងចាំ យល់ដឹង អនុវត្តន៍ វិភាគ វាយតម្លៃ និងបង្កើតថ្មី(
- ភាគរយនៃប្រភេទសំណួរ (ឧទាហរណ៍៖ ប្រភេទសំណួរពហុជ្រើសរើស និង សំណួរបើកជាដើម)

ដើម្បីឱ្យសកម្មភាពបង្កើតគម្រោងតេស្ត បានរួមចំណែកក្នុងការលើកកម្ពស់ចំណេះដឹង ដល់គ្រូបង្រៀនទាំងអស់ក្នុងសាលារៀន គណៈគ្រប់គ្រងសាលារៀនអាចមានជម្រើសជាច្រើន ឧទាហរណ៍រៀបចំឱ្យគ្រូបង្រៀនតាមកម្រិតថ្នាក់ស្របទាំងអស់បង្កើតគម្រោងលម្អិតតេស្តវង្វាយតម្លៃប្រចាំខែកម្រិតសាលារៀន ជាមួយគ្នាដើម្បីឱ្យគេទាំងអស់បានរៀនសូត្រពីគ្នាទៅវិញទៅមក។

## ២. ការតាក់តែងសំណួរតេស្តប្រចាំខែ កម្រិតសាលារៀន

ក្រោយពីគ្រូបង្រៀនតាមកម្រិតថ្នាក់នីមួយៗ បង្កើតបានគម្រោងលម្អិតតេស្តវាយតម្លៃប្រចាំខែរួចហើយ គណៈគ្រប់គ្រងសាលារៀនបន្តដឹកនាំគ្រូបង្រៀនដើម្បីតាក់តែងសំណួរតេស្តប្រចាំខែ ដោយផ្អែកលើគម្រោងលម្អិតតេស្តធ្វើយ៉ាងណាឱ្យខ្លឹមសាររបស់សំណួរតេស្តបានផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស និងមានកម្រិតពុទ្ធិឬបំណិនពីទាបទៅខ្ពស់ ដែលសិស្សអាចបញ្ចេញសមត្ថភាពបានទៅតាមស្ថានភាពជាក់ស្តែង។

សំណួរតេស្ត ជាធាតុសំខាន់ជាងគេ សម្រាប់ដំណើរការតេស្តទាំងមូល។ សំណួរតេស្ត ត្រូវមានលក្ខណៈទាំងពីរ គឺលក្ខណៈវិទ្យាសាស្ត្រ ពីព្រោះជាវិធីសាស្ត្រពិសោធន៍ និងសិល្បៈ ជាបណ្តុំនីតិវិធីសម្រាប់តាក់តែងសំណួរតេស្តឱ្យបានល្អ(ទម្រង់ការប្រើប្រាស់ពាក្យពេចន៍ រូបភាព...)។ សំណួរតេស្តដែលសមស្របនឹងសមត្ថភាពសិស្សដែលយើងចង់វាស់វែង ពោលគឺខ្លឹមសារនៃសំណួរ និងគោលបំណងនៃការវាយតម្លៃ ត្រូវរៀបចំឱ្យមានលក្ខណៈសមស្រប។ សំណួរត្រូវមានទម្រង់សំណង់សំណួរច្បាស់លាស់ ដោយមិនស្រពិចស្រពិល។ សំណួរដែលទាក់ទងជំនាញ ក្នុងការត្រិះរិះ ការវិភាគ ការធ្វើសំយោគ និងការវាយតម្លៃផ្សេងៗ ដោយមិនមែនជាសំណួរ ដើម្បីរំឭកការចងចាំ ឬអនុវត្តន៍ធម្មតានោះឡើយ។ ចំណុចគួរចៀសវាង គឺប្រធានមានលក្ខណៈបញ្ឆោត សំណួរកំប៉ិកកំប៉ុក ប្រើពាក្យ(ឬវត្ថុ)ដែលកុមារនៅតំបន់ផ្សេងទៀតមិនអាចយល់ ប្រើឃ្លា-ប្រយោគវែង សរសេរស្មុគស្មាញ ប្រធានមិនត្រឹមត្រូវ មិនស៊ីសង្វាក់នឹងប្រធាន ប្រយោគបដិសេធ សំណួនវោហារខ្លាំងពេក...។ល។

ប្រភេទសំណួរតេស្តមានដូចជា៖ (១)សំណួរតេស្តដែលមានចម្លើយជ្រើសរើស រួមមានសំណួរពហុជ្រើសរើស សំណួរត្រូវខុស និងសំណួរផ្គូផ្គង (២)សំណួរដែលមានចម្លើយសរសេរ រួមមានសំណួរសរសេរទម្រង់ខ្លី និងសំណួរសរសេរទម្រង់វែង។ ម្យ៉ាងវិញទៀតរាល់សំណួរតេស្ត ត្រូវរៀបចំទៅតាមកម្រិតលំបាករបស់វា ក្នុងនោះមានសំណួរងាយ សំណួរមធ្យម និងសំណួរលំបាកទៅតាមចំណែកថ្នាក់វត្ថុបំណងនៃការអប់រំរបស់ទ្រឹស្តីប្លូមមាន៖ វិស័យពុទ្ធិទាក់ទងទៅនឹងសមត្ថភាព បញ្ញា វិស័យហប្ញទ័យទាក់ទងនឹងចំណូលចិត្តឥរិយាបថ និងវិស័យចិត្តចលករទាក់ទងនឹងបំណិនចលនា។ (សូមមើលឧទាហរណ៍ **សំណួរតេស្ត** សម្រាប់វិញ្ញាសាប្រឡងប្រចាំខែ ក្នុងឧបសម្ព័ន្ធទី៣)

## ៣. ការវិភាគលើសំណួរតេស្ត

ក្រោយពីបានតាក់តែងសំណួរតេស្តរួចស្រេចហើយ គ្រូបង្រៀនថ្នាក់ស្របអាចពិនិត្យមើលឡើងវិញអំពីសំណួរតេស្តនីមួយៗថា តើពេញលេញ គ្រប់គ្រាន់ និងសមស្របទៅនឹងសមត្ថភាពសិស្សដែរឬទេ។ ក្នុងនោះមានសូចនាករ បីដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់ គឺ(១)កម្រិតលំបាកនៃសំណួរ (២)កម្រិតបែងចែកតាមកម្រិតសមត្ថភាពសិស្សនៃសំណួរ (៣)ប្រសិទ្ធភាពនៃជម្រើសចម្លើយខុស។

គ្រប់សំណួរតេស្តទាំងអស់ ក្រុមគ្រូបង្រៀនតាមកម្រិតថ្នាក់ត្រូវកសាងអត្រាកំណែសម្រាប់សំណួរទម្រង់បើក ដើម្បីប្រើប្រាស់ក្រោយពេលធ្វើតេស្តប្រចាំខែ។ (សូមមើលឧទាហរណ៍ **សំណួរតេស្ត** សម្រាប់វិញ្ញាសាប្រឡងប្រចាំខែ ក្នុងឧបសម្ព័ន្ធទី៣)។ ផលប្រយោជន៍របស់អត្រាកំណែតេស្តប្រចាំខែ មានលើសពីការប្រើប្រាស់សម្រាប់កែកិច្ចការតេស្តប្រចាំខែសិស្សទៅទៀត។ វាបានប្រាប់ពីប្រភេទ និងកម្រិតខ្លឹមសារមេរៀន ដែលសិស្សត្រូវចេះក្រោយពីបានរៀនមេរៀនរួច ព្រមជាមួយគ្នានោះក៏បានបង្ហាញជាគំនិតរួមមួយដែលអាចជួយក្នុងការរៀបចំសកម្មភាពបង្រៀនមួយចំនួនផងដែរ។ លើសពីនេះទៅទៀត វាក៏មានតួនាទីសំខាន់ក្នុងការកំណត់មុខសញ្ញាសិស្សជួបការលំបាក ក្នុងការសិក្សា

មេរៀនដែលគ្រូបានបង្រៀនកន្លងមក។ តាមរយៈការអនុវត្តតេស្តនេះ គ្រូបង្រៀនអាចដឹងពីបញ្ហា និងការលំបាកជាក់ស្តែងដែលសិស្សជួបប្រទះ និងអាចរិះរកមធ្យោបាយជួយជាបន្ទាន់ ហើយចំគោលដៅទៀតផង។( សូមមើលឧទាហរណ៍ វិញ្ញាសាប្រឡងប្រចាំខែ ក្នុងឧបសម្ព័ន្ធ ទី៤ )

# ២ ការរៀបចំកម្មវិធី និងកាលវិភាគធ្វើតេស្តសិស្សប្រចាំខែ

គណៈគ្រប់គ្រងសាលារៀនណែនាំដល់សិស្ស គ្រូបង្រៀន អាណាព្យាបាល និងសហគមន៍អំពីសារៈសំខាន់ និងទំនាក់ទំនងរវាងសកម្មភាពវាយតម្លៃលទ្ធផលសិក្សា ក្នុងដំណើរការបង្រៀនប្រចាំថ្ងៃ ជាមួយសកម្មភាពធ្វើតេស្តប្រចាំខែរបស់សាលារៀន ដែលជាមូលដ្ឋានក្នុងការបង្កើនទេពកោសល្យបង្រៀនរបស់គ្រូ និងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ស្របតាមកម្មវិធីសិក្សា និងស្តង់ដាលទ្ធផលសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូចនេះដើម្បីអនុវត្តការងារធ្វើតេស្តប្រចាំខែ មានប្រសិទ្ធភាពដែលអាចវាស់ស្ទង់អំពីកម្រិតលទ្ធផលសិក្សារបស់សិស្សមានលក្ខណៈផ្លូវការ មិនមានភាពលំអៀង គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំឱ្យមានការព្រមព្រៀងគ្នាជាមួយរវាងសិស្ស គ្រូបង្រៀន អាណាព្យាបាលសិស្ស និងសហគមន៍អំពីសកម្មភាពអន្តរាគមន៍ កម្មវិធីធ្វើតេស្ត និងកាលវិភាគធ្វើតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែក្នុងសាលារៀន។

ដើម្បីឱ្យការធ្វើតេស្តប្រចាំខែ ទទួលបានលទ្ធផលប្រសើរ និងមានប្រសិទ្ធភាព (១)គ្រូបង្រៀនត្រូវផ្តល់ព័ត៌មានអំពីការធ្វើតេស្តប្រចាំខែរបស់សាលារៀនដើម្បីឱ្យសិស្ស និងអាណាព្យាបាលសិស្សបានដឹងជាមុន និងឱ្យមានការព្រមព្រៀងជាមួយគ្នា ជាពិសេសការកំណត់ពេលវេលា (២)គ្រូបង្រៀនត្រូវព្រមព្រៀងជាមួយគណៈគ្រប់គ្រងសាលារៀនអំពីកម្មវិធី ពេលវេលា និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងសកម្មភាពធ្វើតេស្តលទ្ធផលសិក្សារបស់សិស្សប្រចាំខែកម្រិតសាលារៀន (៣)គណៈគ្រប់គ្រងសាលារៀន ត្រូវមានការព្រមព្រៀងគ្នាអំពីកម្មវិធី និងពេលវេលាធ្វើតេស្តនៅសាលារៀនជាមួយសហគមន៍ដើម្បីឱ្យសហគមន៍អាចចូលរួមបាន និងគាំទ្រសកម្មភាពធ្វើតេស្តរបស់សាលារៀន។ ( សូមមើលឧទាហរណ៍ **គំរូកម្មវិធី និងពេលវេលា** ធ្វើតេស្តសិស្សប្រចាំខែ ក្នុងឧបសម្ព័ន្ធទី៥ )

ចំពោះការធ្វើតេស្តប្រចាំខែ ដែលប្រព្រឹត្តទៅនៅសាលារៀន គឺផ្តោតទៅលើលទ្ធផលសិក្សា ដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិតរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការធ្វើតេស្តប្រចាំខែ គឺដើម្បីជួយឱ្យគ្រូបង្រៀនមានលទ្ធភាពជួយសិស្សទាន់ពេលវេលា ទាំងសិស្សរៀនយឺត និងសិស្សរៀនលឿន ដោយឆ្លុះបញ្ចាំងពីសកម្មភាព និងវិធីសាស្រ្តបង្រៀនរបស់ខ្លួនក្នុងខែកន្លងមក តាមរយៈការផ្ទៀងផ្ទាត់ជាមួយលទ្ធផលតេស្តប្រចាំខែ ដើម្បីកែលម្អការបង្រៀនឱ្យកាន់តែប្រសើរមួយកម្រិតថែមទៀត។

ចំពោះការវាយតម្លៃ ប្រព្រឹត្តទៅនៅក្នុងថ្នាក់រៀន ដែលផ្សារភ្ជាប់ជាមួយនឹងសកម្មភាពបង្រៀនសិស្សទៅតាមមេរៀននីមួយៗជារៀងរាល់ថ្ងៃ គឺជាមូលដ្ឋានដ៏សំខាន់បំផុត ដែលអាចធានាឱ្យសម្រេចបាននូវលទ្ធផលតេស្តប្រចាំខែរបស់សិស្ស។ ប្រសិនបើការបង្រៀនរបស់គ្រូមិនមានវិធីសាស្រ្តណា ដែលអាចជួយឱ្យសិស្សរៀនបានប្រសើរទេនោះ វានឹងជះឥទ្ធិពលទៅលើលទ្ធផលតេស្តប្រចាំខែជាក់ជាមិនខាន។ ដូច្នេះការបង្រៀនរបស់គ្រូគួរផ្តោតទៅលើវិធីសាស្រ្តបង្រៀនមួយណា ដែលគាត់អាចធ្វើបានទៅតាមលក្ខណៈ និងប្រភេទមេរៀន រួមជាមួយចំណេះដឹង និងបំណិនរបស់

គ្រូបង្រៀនម្នាក់ៗផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ គោលការណ៍ដែលគួរចងចាំនោះ គឺធ្វើយ៉ាងណាអាចជួយឱ្យសិស្សទាំងអស់សប្បាយរីករាយក្នុងសកម្មភាពសិក្សា ដែលជាមូលដ្ឋានសម្រាប់បង្កើតឱ្យសិស្សមានចំណាប់អារម្មណ៍ និងមានទឹកចិត្តប្រឹងប្រែងហ្វឹកហាត់ជាបន្តបន្ទាប់ ដោយភាពម្ចាស់ការ។ ព្រមជាមួយគ្នានោះដែរសិស្សក៏មានមោទនភាពទៅលើលទ្ធផលនៃការសិក្សារបស់គេ តាមរយៈសកម្មភាពបង្រៀនរបស់គ្រូមានដូចជា៖ (១)ការវាយតម្លៃតាមរយៈការងារក្នុងថ្នាក់ (២)ការវាយតម្លៃតាមរយៈកិច្ចការផ្ទះ (៣)ការងារគម្រោង (៤)ការងារសង្កេតតាមដាន (៥)ការសម្ភាសន៍ (៦)ការសម្តែង (៧)ករណីសិក្សា (៨)ការធ្វើបទបង្ហាញ (៩)ការស្ទង់មតិ (១០)ការរកឯកសារមកគាំទ្រឬឯកសារយោង (១១)ការផលិតវីដេអូឬវីដេអូឯកសារ (១២)ការចូលរួមផ្ទាល់ (១៣)ស្វ័យវាយតម្លៃ (១៤)វាយតម្លៃមិត្តភក្តិ និង(១៥)កម្រងកិច្ចការសិក្សា។ល។

# គ ការរៀបចំដំណើរការធ្វើតេស្តប្រចាំខែ

គណៈគ្រប់គ្រងសាលារៀន ធ្វើការជាមួយក្រុមបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងសាលារៀន(គគស) រៀបចំកម្មវិធីធ្វើតេស្តប្រចាំខែរបស់សាលារៀន ដែលអាចធានាបាននូវភាពត្រឹមត្រូវ និងមិនលម្អៀងទៅលើលទ្ធផលសិក្សារបស់សិស្សពីថ្នាក់មួយទៅថ្នាក់មួយទៀតក្នុងសាលារៀន ដែលបានមកពីការធ្វើតេស្តប្រចាំខែរបស់សាលារៀនគ្រប់មុខវិជ្ជានិងគ្រប់កម្រិតថ្នាក់។ ដើម្បីអាចអនុវត្តកិច្ចការនេះតម្លាភាព និងប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀនត្រូវជ្រើសរើសគ្រូបង្រៀនក្នុងសាលារៀនឱ្យប្តូរថ្នាក់គ្នាដើម្បីធ្វើជាអនុរក្សសម្រាប់គ្រប់គ្រងសកម្មភាពធ្វើតេស្ត កំណែតេស្ត និងបូកសរុបលទ្ធផលតេស្ត។ ចំណែកឯបុគ្គលិកផ្សេងទៀតក្នុងសាលារៀន គឺជាអ្នកជួយគ្រប់គ្រងវិន័យ និងសណ្តាប់ធ្នាប់ ដោយទប់ស្កាត់ការយកឯកសារ និងឧបករណ៍អេឡិចត្រូនិចចូលក្នុងកន្លែងធ្វើតេស្ត។ ម្យ៉ាងទៀតដើម្បីបង្ហាញពីតម្លាភាពនៃការធ្វើតេស្ត សាលារៀនត្រូវចាត់អញ្ជើញគណៈកម្មការគ្រប់គ្រងសាលារៀន(គគស) សហគមន៍ មាតាបិតាសិស្ស និងតំណាងក្រុមប្រឹក្សាកុមារឱ្យបានចូលរួមសង្កេត និងតាមដានដំណើរការធ្វើតេស្តនេះផងដែរ។

## ១. មុនពេលធ្វើតេស្តប្រចាំខែ

គណៈគ្រប់គ្រងសាលារៀន ដឹកនាំការប្រជុំជាមួយគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ដើម្បីបែងចែកភារកិច្ចជួយធ្វើកិច្ចការសំខាន់ៗឱ្យបានរួចរាល់មុនពេលដំណើរការធ្វើតេស្ត។ កិច្ចការទាំងនេះមានដូចជា៖(១)រៀបចំបញ្ជីឈ្មោះសិស្សដែលត្រូវធ្វើតេស្តទៅតាមលំដាប់អក្ខរក្រម (២)រៀបចំបញ្ជីឈ្មោះអនុរក្ស ដោយបញ្ជាក់តួនាទី និងភារកិច្ចក្នុងដំណើរការគ្រប់គ្រងការធ្វើតេស្តសិស្ស (៣)រៀបចំបញ្ជីឈ្មោះបុគ្គលិកសិក្សាចូលរួមទទួលខុសត្រូវលើការគ្រប់គ្រងវិន័យ និងសណ្តាប់ធ្នាប់ក្នុងដំណើរការធ្វើតេស្ត (៤)រៀបចំផែនទីឬប្លង់បន្ទប់សម្រាប់ប្រើក្នុងការធ្វើតេស្ត (៥)ត្រួតពិនិត្យវិញ្ញាសាធ្វើតេស្តឡើងវិញ និងត្រៀមថតចម្លងឱ្យបានរួចរាល់ជាមុន។ល។

ក្រោយពីបានត្រៀមកិច្ចការខាងលើរួចរាល់ហើយ គណៈគ្រប់គ្រងសាលារៀន ដឹកនាំការប្រជុំម្តងទៀតជាមួយគ្រូបង្រៀន និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីផ្ទៀងផ្ទាត់កិច្ចការដែលបានរៀបចំកន្លងមក និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីព្រឹត្តិការណ៍ធ្វើតេស្តប្រចាំខែរបស់សាលារៀន ដែលអាចឱ្យសិស្សបានត្រៀមខ្លួន និងប្រឹងប្រែងរៀនសូត្រ ចំណែកគ្រូបង្រៀនក៏បានជួយសិស្សឱ្យហ្វឹកហាត់កាន់តែស្ទាត់ រីឯអាណាព្យាបាលសិស្ស និងសហគមន៍វិញ ក៏

បានដឹងឮអំពីព្រឹត្តិការណ៍នៃធ្វើតេស្តសិស្សរបស់សាលារៀន ដែលអាចឱ្យគាត់មានឱកាសជំរុញកូនចៅរបស់គាត់ឱ្យខិតខំរៀនសូត្របន្ថែមនៅផ្ទះ និងអាចឆ្លៀតពេលចូលរួមសង្កេតសកម្មភាពធ្វើតេស្តនៅសាលារៀនទៀតផង។

## ២. ក្នុងពេលធ្វើតេស្តប្រចាំខែ

គណៈគ្រប់គ្រងសាលារៀនរៀបចំឱ្យមានការជួបជុំមួយ មុនពេលដំណើរការធ្វើតេស្ត ដើម្បីត្រួតពិនិត្យវត្តមាន និងអវត្តមានអ្នកដែលមានភារកិច្ច ក្នុងដំណើរការធ្វើតេស្តសិស្សប្រចាំខែ និងអាចធ្វើការណែនាំបន្ថែមអំពីការទំនួលខុសត្រូវក្នុងការអនុវត្តភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។

ក្រោយទទួលបានការណែនាំពីគណៈគ្រប់គ្រងសាលារៀនរួចហើយ អនុរក្សទាំងអស់យកបញ្ជីឈ្មោះសិស្ស ឯកសារពាក់ព័ន្ធ និងសម្ភារៈមួយចំនួនពីទីចាត់ការ និងទៅកាន់បន្ទប់ធ្វើតេស្ត ដើម្បីពិនិត្យមើលតុកៅអី សរសេរលេខតុ កៅអី ត្រៀមក្តារខៀនឱ្យរួចស្រេច មុនពេលដំណើរការធ្វើតេស្តជាផ្លូវការ។ ចំពោះបុគ្គលិកទទួលផ្នែកវិន័យសណ្តាប់ធ្នាប់ និងអ្នកត្រួតពិនិត្យដំណើរការតេស្តត្រូវទៅកាន់ទីកន្លែងដែលគណៈគ្រប់គ្រងសាលារៀនប្រគល់ឱ្យ។

ឆ្លៀតឱកាសនោះដែរ នាយកសាលាព្យាយាមគប្បីរកពេលវេលានិយាយពន្យល់ណែនាំដល់អាណាព្យាបាលសិស្ស និងសហគមន៍ដែលបានចូលរួមសង្កេតការណ៍ អំពីផលប្រយោជន៍ និងសារៈសំខាន់នៃការធ្វើតេស្តសិស្សប្រចាំខែ របស់សាលារៀន ដើម្បីឱ្យគាត់មានទំនុកចិត្តទៅលើការគ្រប់គ្រងបច្ចេកទេសរបស់សាលារៀន និងជាមធ្យោបាយក្នុងការទាក់ទាញឱ្យគាត់ពេញចិត្ត អាចបន្តផ្សព្វផ្សាយអំពីសារៈសំខាន់នេះទៅដល់ប្រជាជនផ្សេងទៀតក្នុងមូលដ្ឋាន។

ក្នុងពេលដំណើរការធ្វើតេស្ត គណៈគ្រប់គ្រងក៏ត្រូវរៀបចំឱ្យមាន ការផ្តល់សញ្ញាពេលចាប់ផ្តើម និងពេលជិតដល់ម៉ោងបញ្ចប់ការធ្វើវិញ្ញាសាតេស្តរយៈពេល១៥នាទីមុន។ល។ ដើម្បីឱ្យសិស្សអាចត្រៀមខ្លួនជាមុន និងសម្រាប់ឱ្យដំណើរការធ្វើតេស្តអាចប្រព្រឹត្តទៅបានដូចគ្នា មិនឱ្យលើសម៉ោង និងមិនឱ្យខ្វះម៉ោង រវាងបន្ទប់ធ្វើតេស្តមួយ ទៅបន្ទប់ធ្វើតេស្តមួយផ្សេងទៀត។

## ៣. ក្រោយពេលធ្វើតេស្តប្រចាំខែ

គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធត្រូវត្រួតពិនិត្យ អំពីចំនួនកិច្ចការតេស្តសិស្ស បញ្ជីវត្តមានសិស្សចូលរួមធ្វើតេស្ត និងឯកសារចាំបាច់ផ្សេងទៀតដែលអនុរក្សប្រគល់ឱ្យ។ បន្ទាប់មកគណៈគ្រប់គ្រងចាត់ចែងក្រុមកំណែដោយត្រូវកែសន្លឹកកិច្ចការផង និងអ្នកត្រួតពិនិត្យដំណើរការកំណែផង។ ការកែតេស្តសិស្សត្រូវផ្អែកលើអត្រាកំណែដែលគ្រូបង្រៀនបានរៀបចំជាមួយសំណួរតេស្តដែលបានប្រគល់ជូនគណៈគ្រប់គ្រងសាលាមុនដំណើរការតេស្ត។

ក្រោយពីកែកិច្ចការសិស្សរួចស្រេចហើយ ក្រុមកំណែនីមួយៗ (១)ត្រូវស្រង់លទ្ធផលតេស្តរបស់សិស្សម្នាក់ៗ តាមបន្ទប់ធ្វើតេស្ត។ (សូមមើលឧទាហរណ៍ **តារាងកត់ត្រាលទ្ធផលសិក្សារបស់សិស្សតាមថ្នាក់** បានមកពីការធ្វើតេស្តប្រចាំខែ ក្នុងឧបសម្ព័ន្ធ ទី៦) (២)ស្រង់ចំនួនសិស្សសរុបដែលជាប់តេស្ត និងធ្លាក់តេស្តតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់។ រីឯបញ្ជីចំនួនសិស្សសរុបជាប់និងធ្លាក់ (សូមមើលឧទាហរណ៍ **បញ្ជីចំនួនសិស្សសរុបជាប់តាមថ្នាក់** បានមកពីការធ្វើតេស្តប្រចាំខែ ក្នុងឧបសម្ព័ន្ធ ទី៧) អាចជួយឱ្យគណៈគ្រប់គ្រងសាលារៀន ប្រើសម្រាប់ផ្សព្វផ្សាយដល់

សហគមន៍ និងសម្រាប់លើកជារបៀបវារៈប្រជុំពិភាក្សាជាមួយគ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហា ក្នុងករណីមានសិស្សធ្លាក់ច្រើន ឬចំនួនសិស្សជាប់មិនមានការកើនឡើង។

## ឃ ការផ្តល់ព័ត៌មានត្រឡប់ ក្រោយពីការធ្វើតេស្តប្រចាំខែ

ការផ្តល់ព័ត៌មានត្រឡប់មានច្រើនវិធីដែលគ្រូបង្រៀនធ្លាប់បានអនុវត្តកន្លងមកដូចជា៖ (១)ការដាក់ពិន្ទុនិងមូលវិចារលើកិច្ចការសិស្សម្នាក់ៗ (២)គ្រូបង្រៀនដឹកនាំកែលំហាត់ ចំណោទ មេរៀន។ល។ ដោយការពន្យល់ផ្ទាល់មាត់ជាមួយសិស្សទាំងអស់ក្នុងថ្នាក់។ (៣)គ្រូបង្រៀនផ្តល់ឱកាសឱ្យសិស្សដែលស្ម័គ្រចិត្ត ជាពិសេសសិស្សពូកែឡើងកែលើក្តារខៀន ដោយមានការសម្របសម្រួលបន្ថែមពីគ្រូបង្រៀន។ (៤)គ្រូបង្រៀនសរសេរពន្យល់ និងរៀបរាប់ឡើងវិញលើកិច្ចការសិស្ស។ល។ ដូចនេះការផ្តល់ព័ត៌មានត្រឡប់ គ្រូបង្រៀនអាចបន្តអនុវត្តជាក់ស្តែងតាមដែលអាចធ្វើបាន។

គោលបំណងនៃការផ្តល់ព័ត៌មានត្រឡប់ គឺជាការលើកទឹកចិត្តដល់សិស្សរៀនយឺត ឱ្យមានកម្លាំងចិត្តខំរៀន និងមានទំនុកចិត្តពីលទ្ធផលតេស្ត ប៉ុន្តែមិនមែនជាសកម្មភាព ក្នុងការដាក់សម្ពាធបន្ថែមដល់សិស្សរៀនយឺតនោះទេ។ ជួនកាលស្ថានភាពនៃការផ្តល់ព័ត៌ត្រឡប់ខ្លះ មិនបានធ្វើឱ្យសិស្សរៀនយឺតមានកម្លាំងចិត្ត និងទទួលបានចំណេះដឹងបន្ថែមទេ តែបែរជាធ្វើឱ្យសិស្សរៀនយឺតកាន់តែជួបការលំបាក និងមានភាពស្មុគស្មាញ ដោយសាររបៀបនៃការផ្តល់ព័ត៌មានត្រឡប់កើតឡើងពីអាកប្បកិរិយាអវិជ្ជមាន ពាក្យសំដីរបស់សិស្សដែលរៀនពូកែ និងដោយសារមានគ្រូបង្រៀនខ្លះបានយកឱកាសនេះស្តីបន្ទោស និងបន្ទុះបង្អាប់សិស្សរៀនយឺតបន្ថែមទៀត។

មានរបៀបផ្តល់ព័ត៌មានត្រឡប់មួយចំនួនទៀត ដែលគ្រូបង្រៀនគួរពិចារណា យកទៅអនុវត្តមានដូចជា៖

### ១. គ្រូជាមួយសិស្សរៀនយឺតម្នាក់

គ្រូបង្រៀនរកឱកាសនិងទីកន្លែងជាក់ស្តែង ជួបជាមួយសិស្សរៀនយឺតតែម្នាក់(គ្រូមួយទល់សិស្សមួយ) ដើម្បីពិគ្រោះយោបល់ជាមួយគ្នា មានន័យថា គ្រូត្រូវបង្ហាញពីចិត្តអាណិតអាសូរ សម្តែងពីការចូលរួមលំបាក និងមានទឹកចិត្តចង់ជួយសិស្សច្រើនជាជាងការកែលំហាត់ ឬសំណួរ។ សកម្មភាពរបស់គ្រូបង្រៀនបែបនេះ អាចធ្វើឱ្យសិស្សមានភាពកក់ក្តៅ និងហ៊ាននិយាយប្រាប់គ្រូត្រង់ៗពីការលំបាករបស់គេក្នុងការសិក្សា ដោយមិនសូវមានការលាក់លៀមច្រើនពេកទេ។ លទ្ធផលនៃការពិគ្រោះយោបល់ គ្រូបង្រៀនអាចរកឃើញបញ្ហាមួយចំនួន ដែលអាចកើតមានឡើងដោយសារសិស្សខ្សោយបញ្ញា និងអាចដោយសារកត្តាផ្សេងទៀត ដែលកើតមានឡើងទាក់ទងនឹងស្ថានភាពគ្រួសារ និងសង្គមដែលសិស្សរស់នៅ។ ឆ្លៀតឱកាសក្នុងពេលពិគ្រោះយោបល់ គ្រូបង្រៀនអាចសាកល្បង ផ្តល់ដំបូន្មានពីរបៀបរៀន ដោយចាប់ផ្តើមពីខ្លឹមសារមេរៀនងាយៗមួយចំនួន ដែលសិស្សអាចរៀនបាន។ ការផ្តល់ព័ត៌មានត្រឡប់រវាងគ្រូនិងសិស្សម្នាក់ៗនេះគ្រូអាចជ្រើសរើសយកសិស្សរៀនយឺតចំនួន ២ ឬ ៣នាក់តាមដែលអាចធ្វើទៅបាន។

### ២. គ្រូជាមួយសិស្សរៀនយឺតមួយក្រុមតូច

គ្រូបង្រៀនរកឱកាស និងទីកន្លែងជាក់ស្តែងជួបជាមួយក្រុមសិស្ស ដែលជាសិស្សរៀនយឺតប្រហាក់ប្រហែលគ្នា(គ្រូមួយទល់សិស្សមួយក្រុម) ដើម្បីពិគ្រោះយោបល់ជាមួយពួកគេ និងស្តាប់ការរ៉ាយរ៉ាប់ពីការលំបាក ដែលអាច

កើតឡើងដោយសារបៀបរៀន ប្រភេទមេរៀន ការបង្រៀនលឿន អវត្តមានមិនបានរៀន និងបញ្ហាផ្សេងទៀតក្រៅពីដំណើរការសិក្សាជាមួយគ្រូបង្រៀន។ គ្រូព្យាយាមស្វែងយល់អំពីចំណុចលំបាករួម និងចំណុចលំបាកដោយឡែកសម្រាប់រៀបចំសកម្មភាពអន្តរាគមន៍។ ក្រៅពីស្តាប់ការរ៉ាយរ៉ាប់របស់សិស្ស គ្រូក៏អាចផ្តល់ឱកាសឱ្យសិស្សលើកសំណូមពរមកគ្រូបង្រៀនវិញ ដែលទាក់ទងនឹងរបៀបបង្រៀនរបស់គ្រូ មានដូចជាបង្រៀនលឿនពេក ពន្យល់មិនច្បាស់ ពន្យល់សង្ខេបពេក ការរំខានពីសិស្សគ្នាឯងក្នុងថ្នាក់ ឬការលំបាកក្នុងជីវភាពរស់នៅ។ល។

ក្រោយពីបានស្តាប់យោបល់ និងសំណូមពររបស់ក្រុមសិស្សរួចហើយ គ្រូបង្រៀនអាចសន្យាអនុវត្តតាម និងជួយដាស់តឿនក្រុមសិស្សរៀនយឺតឱ្យចេះជួយគ្នា អប់រំគ្នា ពន្យល់គ្នា និងចេះរៀនជាមួយគ្នា ក្នុងករណីសិស្សណាម្នាក់មានចំណេះដឹងច្រើនជាងគេ លើចំណុច និងខ្លឹមសារណាមួយ ដោយសារតែសិស្សរៀនយឺតប្រហាក់ប្រហែលគ្នា អាចងាយរៀនពីគ្នាទៅវិញទៅមកផងដែរ។

### ៣. គ្រូជាមួយអាណាព្យាបាលសិស្សរៀនយឺតម្នាក់

គ្រូបង្រៀនរកឱកាស និងទីកន្លែងសមរម្យ ជួបជាមួយអាណាព្យាបាលដែលកូនរៀនយឺត(គ្រូមួយទល់អាណាព្យាបាលមួយ)ដើម្បីពិគ្រោះយោបល់ជាមួយគ្នា។ ជាដំបូងគ្រូបង្រៀនគួរព្យាយាមរៀបរាប់ពីចំណុចវិជ្ជមានរបស់កូនគាត់ជាមុនសិន មុននឹងពិភាក្សាពីបញ្ហានៃការរៀនយឺត ដូចជា៖ ជាក្មេងសុភាពរាបសា មានចិត្តល្អចំពោះមិត្តភក្តិ ចេះស្តាប់បង្គាប់គ្រូ មិនចេះជេរ ឬវាយគេវាយឯង ។ល។

បន្ទាប់មកទើបបង្ហាញពីចំណុចជាក់លាក់ ក្នុងមេរៀនដែលកូនគាត់ជួបការលំបាក។ ការពិគ្រោះយោបល់នេះ គឺសម្រាប់ឱ្យអាណាព្យាបាលបានយល់ពីការលំបាករបស់សិស្ស និងការលំបាករបស់គ្រូបង្រៀន ដើម្បីទាំងពីរនាក់អាចព្រមព្រៀងសហការគ្នា ដើម្បីជួយកូនរបស់គាត់ តាមរយៈសកម្មភាពងាយៗ ដែលគាត់អាចធ្វើបាន ដូចជាឈប់តិះដៀលនិងស្តីជេរកូន ប្តូរមកពិភាក្សាជាមួយកូន ឱ្យកូនអានអត្ថបទឬមេរៀនឱ្យស្តាប់(ក្នុងករណីមិនចេះអក្សរ) ឬហៅកូនឱ្យសរសេរពាក្យពិបាកឬសរសេរតាមអាន។ល។

### ៤. គ្រូជាមួយអាណាព្យាបាលសិស្សរៀនយឺតមួយក្រុម

គ្រូបង្រៀនរកឱកាសនិងទីកន្លែងសមរម្យ ជួបជាមួយអាណាព្យាបាល ដែលកូនរៀនយឺតមួយក្រុម(គ្រូមួយទល់អាណាព្យាបាលមួយក្រុម)ដើម្បីពិគ្រោះយោបល់ជាមួយគ្នា ដោយព្យាយាមរៀបរាប់ពីចំណុចវិជ្ជមានរបស់កូនគាត់ និងព្រមព្រៀងសហការគ្នាក្នុងការជួយកូនគាត់ជាមួយគ្នា តាមរយៈសកម្មភាពងាយៗនៅផ្ទះ និងសកម្មភាពឱ្យសិស្សរៀនយឺត បានរៀនបន្ថែមជាមួយគ្រូ ជាមួយសិស្សច្បង ឬជាមួយយុវជនដែលស្ម័គ្រចិត្តជួយសិស្សរៀនយឺតដោយប្រើប្រាស់ម៉ោងរៀនពេលល្ងាចឬព្រឹក ឬពេលសម្រាក។ល។

### ៥. គ្រូជាមួយអាណាព្យាបាលសិស្សរៀនលឿនម្នាក់

គ្រូបង្រៀនរកឱកាសនិងទីកន្លែងជាក់ស្តែង ជួបជាមួយអាណាព្យាបាល ដែលកូនរៀនលឿន(គ្រូមួយទល់អាណាព្យាបាលមួយ) ដើម្បីប្រាប់គាត់ឱ្យបានដឹងអំពីគុណសម្បត្តិកូនរបស់គាត់រៀនលឿន(ឆ្លាត) និងបន្តជួយកូន

បន្ថែម។ ម្យ៉ាងវិញទៀតជាការឆ្លៀតឱកាសអបអរសាទរ និងថ្លែងអំណរគុណដល់គាត់។ សកម្មភាពនេះ គឺជាវិធីឃោសនាអំពីការខិតខំប្រឹងប្រែង ការយកចិត្តទុកដាក់របស់គ្រូបង្រៀនចំពោះការសិក្សារបស់សិស្ស និងការខិតខំប្រឹងប្រែងរបស់សាលារៀន។

**៦. នាយកសាលាជាមួយគណៈគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី និងសហគមន៍**

នាយកសាលារៀនផ្តល់ព័ត៌មាន អំពីលទ្ធផលសិក្សាសរុបតាមកម្រិតថ្នាក់ ដែលបានពីការធ្វើតេស្តសិស្សប្រចាំខែ ទៅដល់គណៈគ្រប់គ្រងសាលារៀន និងអាជ្ញាធរដែនដី តាមរយៈកម្មវិធីប្រជុំផ្សេងៗក្នុងមូលដ្ឋាន និងជាពិសេសក្នុងកម្មវិធីប្រជុំក្នុងសាលារៀន។ ជាមួយគ្នានោះដែរនាយកសាលារៀន ត្រូវបិទផ្សាយនៅក្នុងសាលារៀន នៅសាលាឃុំ និងនៅទីកន្លែងផ្សេងទៀតក្នុងមូលដ្ឋាន អំពីលទ្ធផលតេស្តប្រចាំខែសរុបតាមកម្រិតថ្នាក់ ដោយបង្ហាញពីឈ្មោះគ្រូបង្រៀននោះផង ដើម្បីអាចឱ្យអាណាព្យាបាលទូទៅបានដឹង ពីកម្រិតរីកចម្រើននៃលទ្ធផលសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ក្នុងសាលារៀន។ ក្រៅពីនោះនាយកសាលារៀន សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត រួមទាំងក្រុមសាសនា ក៏អាចជួយផ្សព្វផ្សាយបន្ថែមតាមរយៈមេក្រូ និងសកម្មភាពផ្សព្វផ្សាយសាសនាផ្សេងៗ។

# ខ សកម្មភាពហ្វឹកហាត់ជួយសិស្សរៀនយឺត និងលឿន

ការរៀបចំសកម្មភាព ឱ្យសិស្សចេះជួយសិស្សគ្នាឯង ក្នុងការសិក្សាមិនមែនជាកិច្ចការលំបាកពេកនោះទេ ប៉ុន្តែលុះត្រាតែគ្រូបង្រៀន ជួយឱ្យសិស្សក្នុងថ្នាក់មានទឹកចិត្តអាណិតអាសូរគ្នាទៅវិញទៅមកសិន ជាពិសេសចំពោះសិស្សដែលរៀនយឺត និងសិស្សជួបការលំបាកក្នុងជីវភាពរស់នៅ បើមិនដូច្នោះទេ គំនិតនេះគ្រាន់តែជាទ្រឹស្តីតែប៉ុណ្ណោះ។ នៅពេលណាសិស្សមានការយល់ដឹង ពីការលំបាកនិងសុខទុក្ខរបស់មិត្តភក្តិគេហើយ ពេលនោះគេនឹងរិះរកមធ្យោបាយជួយគ្នាដោយភាពម្ចាស់ការលើសពីការរំពឹងទុករបស់គ្រូបង្រៀនទៀតផង។ ស្ថានភាពបែបនេះគ្រូបង្រៀនមិនចាំបាច់ខ្វល់ខ្វាយច្រើនពេកទេ គ្រាន់តែរិះរកមធ្យោបាយ និងល្បិចមួយចំនួនថែមទៀតដែលអាចលើកទឹកចិត្តឱ្យសិស្សអាចជួយគ្នាក្នុងការសិក្សា និងក្នុងសកម្មភាពសង្គម គឺជាការស្រេចទៅហើយ។

**១. កំណត់មុខសញ្ញាសិស្សជួបការលំបាក**

រៀបចំសកម្មភាពសិក្សា ដើម្បីកំណត់មុខសញ្ញាសិស្សជួយការលំបាក ដោយផ្សារភ្ជាប់ការសិក្សាជាមួយមេរៀនសិក្សាសង្គម និងមេរៀនភាសាខ្មែរ តាមរយៈសកម្មភាពអនុវត្តការសរសេរអំពីមនុស្សឬបុគ្គលដែលចាប់អារម្មណ៍ សម្រាប់ធ្វើបទបង្ហាញរបាយការណ៍ដល់សិស្សផ្សេងទៀតក្នុងថ្នាក់។

**ការសរសេរសាវតា និងរឿងរបស់សិស្សម្នាក់ៗ៖** គ្រូបង្រៀនរៀបចំសិស្សជាក្រុមតូច ដែលមានសមាជិក ៣ ទៅ ៤នាក់។ គ្រូណែនាំសិស្សដោយឱ្យគំរូប្លង់សម្រាប់សរសេរ និងលំដាប់លំដោយក្នុងការសរសេរ។ ដើម្បីសរសេរបានសាវតារ និងប្រវត្តិរបស់សិស្សម្នាក់ៗ សិស្ស ៣នាក់ ជាអ្នកសម្ភាសន៍និងជាអ្នកសរសេរ រីឯសិស្សម្នាក់ទៀតត្រូវបានគេសម្ភាសន៍រកព័ត៌មានសម្រាប់សរសេរ។ ការសរសេរនេះសិស្សត្រូវប្តូរភារកិច្ចគ្នា លុះត្រាតែសិស្សម្នាក់ៗបានសរសេរចងក្រងអំពីសាវតារនិងប្រវត្តិ ដែលអាចបង្ហាញពីការលំបាក ការតស៊ូ និងសេចក្តីព្យាយាមក្នុងការសិក្សា អំពីជីវភាពរស់នៅ និងភាពកម្សត់ផ្សេងទៀត សម្រាប់សិស្សមួយចំនួនតូចដែលកំពុងប្រឈមក្នុងការរស់នៅ។ លទ្ធផលនៃការសរសេររឿងបានជួយឱ្យសិស្ស មានទឹកចិត្តអាណិតអាសូរគ្នា ព្រមជាមួយគ្នានោះអាចមានសិស្សមួយចំនួន

បានលួចឆ្លុះបញ្ចាំងពីជីវិតរស់នៅរបស់គ្រួសារខ្លួនទៅនឹងសិស្សមួយចំនួនដែលជួបការលំបាកផងដែរ។ (សូមមើលឧទាហរណ៍ **ប្លង់សាវតារនិងរឿងរ៉ាវជីវិតរបស់សិស្ស** ក្នុងឧបសម្ព័ន្ធ ទី៨)

**ការធ្វើបទបង្ហាញសរសេរសាវតារ និងរឿងរបស់សមាជិកក្រុម៖** គ្រូបង្រៀនរៀបចំទីកន្លែងដែលមានបរិយាកាសប្រកបដោយចិត្តសាស្ត្រ សម្រាប់ឱ្យសិស្សបានធ្វើបទបង្ហាញអំពីសាវតារ និងរឿងរ៉ាវជីវិតពិតរបស់សមាជិកក្រុមគេ។ អាចប្រើប្រាស់កន្លែងប្រជុំក្នុងសាលា នៅវត្ត ឬកន្លែងណាដែលបង្កើតបានបរិយាកាសជំរុញឱ្យអារម្មណ៍រំភើប។ រីឯអ្នកចូលរួមអាចអញ្ជើញនាយកសាលា គ្រូបង្រៀនថ្នាក់ផ្សេង អាជ្ញធរដែនដី និងអាណាព្យាបាលមួយចំនួនបានចូលរួមស្តាប់ ដើម្បីឱ្យបានដឹងពីស្ថានភាពជីវិតពិតរបស់សិស្សដែលកំពុងប្រឈមក្នុងការសិក្សា និងការរស់នៅ។ បរិយាកាសនេះអាចលើកទឹកចិត្តឱ្យអាណាព្យាបាល និងសហគមន៍មានការយកចិត្តទុកដាក់ដល់សិស្សជួបការលំបាក និងខិតខំជួយកូនចៅក្នុងការរៀនសូត្រ។ ចំណែកគ្រូបង្រៀនវិញបានដឹងរឿងរ៉ាវជីវិតពិតរបស់សិស្ស នាំមកនូវការអាណិតអាសូរដល់សិស្សរបស់ខ្លួន និងដាក់ចិត្តជួយសិស្សតាមរយៈការខិតខំប្រឹងប្រែងបង្រៀន។

**ចលនាធនធានជួយសិស្សជួបការលំបាក៖** គ្រូបង្រៀនអាចរៀបចំជាយុទ្ធនាការក្នុងថ្នាក់រៀន និងជាមួយអាណាព្យាបាលសិស្សក្នុងថ្នាក់ ដើម្បីជួយសិស្សជួបការលំបាក ដូចជាការឧបត្ថម្ភសម្ភារសិក្សា មធ្យោបាយសិក្សា និងការលំបាកមួយចំនួនតាមលទ្ធភាពអាចធ្វើទៅបាន ដែលសកម្មភាពនេះយើងអាចឱ្យឈ្មោះថា **អាហារូបករណ៍ភូមិ**។ ក្រៅពីនោះគ្រូបង្រៀន រកពេលពិភាក្សាជាមួយសិស្សជួបការលំបាក និងសិស្សរៀនយឺត ដើម្បីបានគំនិតសម្រាប់មករៀបចំសកម្មភាពបង្រៀន។

## ២. ប្រកួតសមាជិកក្រុមសិស្សក្នុងថ្នាក់ និងក្លិបសិក្សាតាមខ្នងផ្ទះ

ការរៀបចំការប្រកួតសមាជិកក្រុមសិស្សក្នុងថ្នាក់ និងក្លិបសិក្សាតាមខ្នងផ្ទះ គ្រូបង្រៀនចាំបាច់ត្រូវធ្វើឱ្យមានទំនាក់ទំនងជាមួយនឹងសកម្មភាពតេស្តកម្រិតថ្នាក់រៀន។ មានន័យថា គ្រូបង្រៀនចង់ឱ្យសិស្សមួយចំនួនតូចក្នុងថ្នាក់ចេះអានស្ទាត់ និងចាំរូបមន្ត... ដូចសិស្សឯទៀត ដើម្បីឱ្យការធ្វើតេស្តកម្រិតថ្នាក់រៀងរាល់សប្តាហ៍ និងកម្រិតសាលានាពេលចុងខែ សិស្សជួបការលំបាកទាំងនេះអាចទទួលបានលទ្ធផលតេស្តប្រសើរជាងមុន។ ដូច្នេះគ្រូបង្រៀនគួររៀបចំសកម្មភាពប្រកួតផ្សេងៗដូចបានបញ្ជាក់ក្នុងគោលបំណងខាងលើ។

**ការរៀបចំក្រុមតូចសម្រាប់ប្រកួត៖** មានជម្រើសច្រើន អាស្រ័យលើការសម្រេចចិត្តរបស់គ្រូបង្រៀន អាចរាប់លេខ អាចរាប់តាមលេខរៀងក្នុងសៀវភៅបញ្ជីហៅឈ្មោះ អាចកំណត់មុខសញ្ញាសិស្សដែលនៅភូមិជាមួយគ្នា ។ល។ ក្រុមនីមួយៗត្រូវដាក់ឈ្មោះក្រុម (និមិត្តសញ្ញា/LOGO) ត្រូវកំណត់គោលបំណង និងលក្ខណៈពិសេសរបស់ក្រុម ក្នុងការជួយគ្នាក្នុងការសិក្សារៀនសូត្រ និងយកអាសារគ្នា ក្នុងករណីមានភ័យន្តរាយកើតឡើង។ សិស្សតាមក្រុមបង្ហាញឈ្មោះ និមិត្តសញ្ញា និងគោលបំណងដល់សិស្សក្នុងថ្នាក់ និងមានការដាក់តាំងបង្ហាញក្នុងថ្នាក់ឬនៅកន្លែងណាដែលសមស្រប។

**ការរៀបចំក្រុមតូចសម្រាប់ប្រកួត៖** មានជម្រើសច្រើនអាស្រ័យលើគោលបំណងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់ការប្រកួតជាមធ្យោបាយសម្រាប់ឱ្យសិស្សបានរៀនជាមួយគ្នា សហការគ្នាក្នុងការជួយសិស្សរៀនយឺតក្នុងក្រុម។ ដូច្នេះគ្រូបង្រៀនឱ្យពាក្យ អត្ថបទ និងប្រធានបទជាមុនឱ្យសិស្សរៀនសម្រាប់ត្រៀមប្រកួត។ ធ្វើយ៉ាងនេះដើម្បីឱ្យ

សិស្សក្នុងក្រុមបានរៀនជាមួយគ្នា និងបានជួយដល់សិស្សរៀនយឺតក្នុងក្រុម ជៀសវាងចាញ់ក្រុមផ្សេងនៅពេលប្រកួត ដោយសារត្រូវចាប់ឆ្នោតរើសយកតែសមាជិកម្នាក់ជាតំណាងឱ្យក្រុម ទៅប្រកួតជាមួយក្រុមផ្សេងទៀត។

**ការប្រកួត៖** គ្រូបង្រៀនអាចជ្រើសរើសសិស្ស ដែលស្ម័គ្រចិត្តធ្វើជាគណៈកម្មការប្រកួត ក្រោមការដឹកនាំនិងគ្រប់គ្រងដោយគ្រូបង្រៀនផ្ទាល់។ ការប្រកួតចេះតែបន្តធ្វើពីពេលមួយ ទៅពេលមួយទៀត តាមប្រធានបទ។ ដូច្នេះគ្រូបង្រៀនមានតារាងកត់ត្រាក្រុមទទួលជោគជ័យ ច្រើនជាងគេ និងតិចជាងគេ ដើម្បីឱ្យក្រុមបានចែករំលែកពីយុទ្ធសាស្រ្តរបស់ក្រុម។ តែជាទូទៅចំនួនឈ្នះ មានការប្រែប្រួលជានិច្ចជាកាល អាស្រ័យលើការចាប់ឆ្នោត។ ពេលចាប់ឆ្នោតបានសមាជិកពូកែនឹងមានឱកាសឈ្នះច្រើន។ ធ្វើបែបនេះអាចមានក្រុមខ្លះព្យាយាមឱ្យសមាជិកក្រុម ប្រឹងរៀន និងប្រឹងជួយបង្រៀនរហូតបានជ័យជម្នះ។ គោលបំណងសំខាន់ គឺឱ្យសិស្សជួយសិស្ស ក្នុងសកម្មភាពសប្បាយរីករាយរាល់ពេលប្រកួត។ បើអាចធ្វើទៅបាន គ្រូបង្រៀនអញ្ជើញឱ្យតំណាងអាណាព្យាបាល និងសហគមន៍បានចូលរួមម្តងម្កាល។ ក្នុងខណៈនោះគ្រូបង្រៀនរៀបចំឱ្យមានលិខិតសរសើរដល់ក្រុមសិស្ស និងថ្លែងអំណរគុណដល់តំណាងអាណាព្យាបាលសិស្សពូកែ ដែលកូនបានជួយសិស្ស ក្នុងក្រុមឱ្យទទួលបានជោគជ័យ។

### ៣. ប្រកួតគ្រូបង្វឹកជួយសិស្សរៀនយឺត

ការរៀបចំការប្រកួតសមាជិកក្រុមសិស្សក្នុងថ្នាក់ និងក្លិបសិក្សាតាមខ្នងផ្ទះ គ្រូបង្រៀនចាំបាច់ត្រូវធ្វើឱ្យមានទំនាក់ទំនងជាមួយនឹងសកម្មភាពតេស្តកម្រិតថ្នាក់រៀន។ មានន័យថា គ្រូចង់ឱ្យសិស្សមួយចំនួនតូចក្នុងថ្នាក់ ចេះអានស្ទាត់ និងចាំរូបមន្ត... ដូចសិស្សឯទៀត ដើម្បីឱ្យការធ្វើតេស្តកម្រិតថ្នាក់រៀងរាល់សប្តាហ៍ និងកម្រិតសាលារៀននៅចុងខែ សិស្សដែលជួបការលំបាកទាំងនេះអាចទទួលបាន លទ្ធផលតេស្តប្រសើរជាងមុន។ ដូច្នេះគ្រូបង្រៀនគួររៀបចំសកម្មភាពប្រកួតផ្សេងៗ ដូចបានបញ្ជាក់ក្នុងគោលបំណងខាងលើ។

**ការរៀបចំគ្រូបង្វឹកសម្រាប់ប្រកួត៖** មានជម្រើសច្រើន អាស្រ័យលើការសម្រេចចិត្តរបស់គ្រូបង្រៀន មានដូចជាការជ្រើសរើសសិស្សក្នុងថ្នាក់ដែលរៀនពូកែស្ម័គ្រចិត្ត ឬចាត់តាំងធ្វើជាគ្រូបង្វឹក ដោយមានចំនួន៥០% រីឯ៥០% ទៀត គឺត្រូវធ្វើជាកូនចៅសម្រាប់ឱ្យគេបង្វឹក។ ការរៀបចំក្រុម គឺឱ្យសិស្សជាគ្រូបង្វឹកចាប់ឆ្នោតយកឈ្មោះសិស្សម្នាក់ក្នុងប្រអប់។ ឈ្មោះសិស្សក្នុងសន្លឹកឆ្នោតនោះជាកូនចៅសម្រាប់បង្វឹក។ ការចាប់ឆ្នោតបន្តធ្វើរហូតទាល់តែអស់សមាជិកក្នុងក្រុម។ ដើម្បីឱ្យបរិយាកាសនេះ កាន់តែផ្លូវការអាចមានការចូលរួមពីសំណាក់នាយក ឬនាយករងសាលារៀនផងដែរ បើគិតថា ជាការចាំបាច់។

**ការរៀបចំសកម្មភាពហ្វឹកហាត់មុនពេលប្រកួត៖** មានជម្រើសច្រើន អាស្រ័យលើគោលបំណងរបស់គ្រូបង្រៀន តែមានវិធីមួយចំនួនដែលងាយៗ ដូចជាឱ្យពាក្យពិបាក ឬអត្ថបទជាមុនសម្រាប់ហ្វឹកហាត់អានស្ទាត់។ មុនពេលប្រកួតគ្រូបង្វឹកត្រូវពិភាក្សាជាមួយកូនចៅ ធ្វើផែនការសកម្មភាព និងយុទ្ធសាស្រ្តក្នុងការហ្វឹកហាត់។ សម្រាប់គ្រូបង្រៀនអាចឆ្លៀតឱកាសតាមដានអំពីរបៀបរៀនដែលសិស្សទាំងពីរធ្វើឡើងដោយឡែកៗពីគ្នាលើប្រធានបទដូចគ្នា។

**ការប្រកួត៖** ការប្រកួតមានជម្រើសជាច្រើន តែគួររៀបចំឱ្យទៅជាផ្លូវការបន្តិច ដែលជាចិត្តសាស្រ្តសម្រាប់ឱ្យសិស្សបានយកចិត្តទុកដាក់ក្នុងដំណើរការប្រកួត។ គ្រូបង្រៀនអាចខ្ចីសិស្សពីថ្នាក់ផ្សេង ដែលមានកម្រិតសមត្ថភាពខ្ពស់ជាង មកធ្វើជាគណៈកម្មការដឹកនាំការប្រកួត ឬយកក្រុមប្រឹក្សាកុមាររបស់សាលារៀន ដែលមានតួនាទីពង្រឹងការ

សិក្សារៀនសូត្ររបស់សិស្សទាំងឡាយក្នុងសាលា។ លទ្ធផលប្រកួតត្រូវផ្តល់ឱ្យទៅគ្រូបង្វឹក អាចមានជាលិខិតសរសើរ និងការថ្លែងអំណរគុណ។ល។ ពីសំណាក់មិត្តភក្តិ គណៈគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធ។

**៤. ពិព័រណ៍ស្នាដៃសិស្ស**

